[*អ្នកសម្ភាសៈ សាយ គុណ.* អ្នកផ្តល់បទសម្ភាសន៍ៈ ក្រាក់ ជី]
[*Interviewer: TS.* Interviewee: KC.]

[00:00]

*សូមឲ្យតាជួយណែនាំខ្លួន!*
*Please introduce yourself!*

ខ្ញុំឈ្មោះក្រាក់ ជី។
My name is Krak Chi.

*តាអាយុប៉ុន្មានហើយ?*
*How old are you?*

ខ្ញុំអាយុ៧០ឆ្នាំហើយ។
I am 70 years old now.

*តាមានមុខរបរធ្វើអ្វីដែរ?*
*What is your occupation?*

មុខរបរខ្ញុំធ្វើស្រែ។ ក្រៅពីធ្វើស្រែ ខ្ញុំធ្វើអង្គួច។
My main occupation is rice farming. Besides, I make Angkuoch for survival.

*តាចេះធ្វើអង្គួចតាំងពីពេលណា?*
*When did you learn to make Angkuoch?*

ខ្ញុំចេះធ្វើអង្គួចប្រហែលជាជាងដប់ឆ្នាំហើយ។
I've known how to make Angkuoch for over ten years now.

*ប្រហែលជាឆ្នាំណាដែរ?*
*About what year?*

ខ្ញុំចាំអត់បានដែរ។ [សើច...] ប្រហែលជាឆ្នាំ១៩៩៥ ទៅ១៩៩៦។
I cannot remember. [ laughs...] Perhaps around 1995 to 1996.

*ហេតុអ្វីតាចាប់អារម្មណ៍ក្នុងការធ្វើអង្គួច?*
*Why were you interested to learn to make Angkuoch?*

ចាស់ៗពីដើមគាត់ធ្វើ ហើយខ្ញុំចេះតែបន្តធ្វើមកទៀត។
Old people in the past liked to make this instrument, so I should continue.

ខ្ញុំអាចរកចំណូលបានខ្លះដែរពីការធ្វើអាជីវកម្មពីឧបករណ៍នេះ។
I also can generate some income from making this instrument.

ការងារនេះជាការងារស្រាល។
Making this instrument does not take so much energy.

ខ្ញុំចំណាយថវិកាតិចលើការចំណាយដើមទុន។
I spend little money on the outlay.

[01:45]

*ចុះតារៀនធ្វើមកពីអ្នកណាដែរ?*
*Who did you learn [to make Angkuoch] from?*

កាលពីមុន ខ្ញុំឃើញចាស់ៗបុរាណធ្វើ។ តែពេលនោះ ខ្ញុំមិនទាន់ចាប់អារម្មណ៍ទេ។
ខ្ញុំនៅក្មេងពេលនោះ។
I saw old people make it, earlier. But, at that time, I was not interested. I was young.

តែដល់ពេលក្រោយមក ដល់ពេលដែលខ្ញុំចាស់ ខ្ញុំនឹកឃើញ។
ខ្ញុំទៅរៀនពីគេអ្នកធ្វើមុន។
...but later on, when I became old, I became interested to learn. I learned from an old maker.

តែក្នុងភូមិខ្ញុំ គ្មានអ្នកណាធ្វើទេ។ មានតែអ្នកនៅព្រះដាក់។
ខ្ញុំទៅមើលគាត់នៅព្រះដាក់។ ភូមិខ្ញុំកាលពីមុនមានដែរ តែគាត់បានស្លាប់ហើយ។
គាត់មិនបានបន្សល់ចំណេះទាំងនោះឲ្យពួកយើងទេ។
In my village, no one makes it [Angkuoch] - only in [the village of] Preah Dak. I went to see him [the maker] making [Angkuoch] in Preah Dak. A long time ago, in my village, there was one maker, but he passed away. He did not leave us knowledge about Angkuoch-making.

តែដល់ពេលក្រោយមក ខ្ញុំទៅភូមិព្រះដាក់។ ហើយកូនខ្ញុំ
គាត់ក៏ទៅទិញគេយកមកលក់ដែរ។
But later, I went to Preah Dak. And my son, he also went to buy Angkuoch from there.

ពេលដែលខ្ញុំឃើញគេធ្វើ ខ្ញុំមានគំនិតថាចង់ធ្វើដែរ។ ក្រោយមក ខ្ញុំក៏រៀនចេះធ្វើ។
When I saw them making [Angkuoch], I got the idea that I want to do it too. Later on, I learned and knew how to make it.

*គាជួយប្រាប់បន្តិចមើលថា អង្គួចមានស្ថានភាពដូចម្ដេចកាលពីមុន?*
*Could you tell me the situation of Angkuoch in earlier times?*

ពីដើមឡើយ ខ្ញុំតែងឃើញចាស់ៗធ្វើសម្រាប់លក់ឲ្យភ្ញៀវទេសចរណ៍។
Before, I saw old people make this instrument to sell to the tourists.

ហើយគាត់ក៏ធ្វើសម្រាប់ផ្ទាត់លេងពេលដែលគាត់ទំនេរ។
And they also made this instrument to play when they are free from work.

គាត់ក៏មានគំនិតលក់ឲ្យទៅភ្ញៀវទេសចរណ៍។ សម្រាប់អ្នកដែលឃើញ
និងចាប់អារម្មណ៍ ពួកគេក៏ទិញឧបករណ៍នេះ។
They had the idea to sell it to the tourists. For those tourists who saw that and were interested, they bought this instrument.

[03:08]

*ចុះគាថា គាធ្លាប់ឃើញតាំងតែពីក្មេងៗ! សូមគាជួយរៀបរាប់បន្ថែម!*
*But you mentioned that you saw this instrument when you were young! Could you tell me more?*

មុនសម័យ ១៩៧០ គេធ្វើសម្រាប់លក់ឲ្យភ្ញៀវទេសចរណ៍ដែរ។ ចាស់ៗធ្វើ
ហើយខ្ញុំមិនបានចាប់អារម្មណ៍ថាចង់ធ្វើទេ។
Before 1970, they made this instrument to sell to the tourists too. Old people made it, but I was not interested then to make it.

តែក្រោយឆ្នាំ១៩៩០ ខ្ញុំចាប់អារម្មណ៍។ ហើយខ្ញុំក៏ទំនេរទើបខ្ញុំរៀនធ្វើ ខ្ញុំក៏បានចេះ។
But after 1990, I started to become interested in the making. And I was also free, so then I learned to make it.

*ពីដើមមានអ្នកទិញអង្កួចច្រើនទេ?*
*Were there many Angkuoch buyers before?*

ពីដើម មានអ្នកទិញច្រើន តែឥឡូវ មានតិចៗទេ។
Before there were many buyers, but now there are fewer.

ពេលចូលឆ្នាំសកល មានអ្នកទិញច្រើនព្រោះអ្នកទេសចរណ៍ក៏មកច្រើន។
When it was new year’s eve, there were a lot of buyers, because many tourists came to visit.

[04:03]

*តែភាគច្រើន អ្នកណាអ្នកទិញ?ភ្ញៀវក្នុងស្រុក ឬក្រៅស្រុក?*
*Who were the buyers? Local or foreign tourists?*

ភាគច្រើនភ្ញៀវក្រៅស្រុក មានដូចជា៖ ចិន បារាំង
និងភ្ញៀវដែលមកលេងអង្គរដ៏ទៃទៀត។
Most of the buyers were foreign tourists such as Chinese, French and other foreigners that came to visit the Angkor temples.

*អញ្ចឹងមានន័យថា នៅពេលដែលគេមកលេងអង្គរ គេទិញអង្កួចដែរ?*
*So it means when the tourists came to visit Angkor temples, they also bought the Angkuoch.*

ពេលដែលគេឃើញក្មេងៗលក់ គេទិញ។ គេលក់តាមកន្លែងរបស់គេ។
When they saw kids selling it, they bought it. Kids sold it at different places.

*អ្នកភូមិតាឬដែលទិលក់អង្កួច?*
*Your villagers are the sellers?*

មានគេមកទិញខ្ញុំ ហើយយកទៅលក់។
There were some people who came to buy [Angkuoch] from me, to sell.

*អត់ទេ ខ្ញុំចង់សំដៅទៅមុនសម័យ១៩៧០។*
*No, I want to refer to the period before 1970.*

មុនសម័យ ១៩៧០ ខ្ញុំជាកូនក្មេង។ តែមានក្មេងៗទិញអង្កួច
ហើយលក់តាមប្រាសាទដូចបែបនេះដែរ។
Before 1970, I was a kid, but there were kids who bought Angkuoch and sold them at the temples.

*អញ្ចឹងតាមានឃើញគេលក់ដែរ?*
*But you also saw people selling Angkuoch at that time?*

ឃើញៗ!
Yes, I did.

[05:10]

*អម្បាញ់មិញ តានិយាយថា តារៀនធ្វើអង្កួចតាំងពីឆ្នាំ១៩៩០។ មែនឬអត់?*
*You said that you learned to make Angkuoch in the 1990s. Is that right?*

បាទ! តាំងតែពីឆ្នាំ១៩៩០ ជាង។
Yes, in the 1990s.

*អញ្ចឹងតាធ្វើតាំងពីពេលនោះមករហូត?*
*So you have kept making them since then?*

ដូចខ្ញុំថាអំបាញ់មិញ!  ពេលខ្ញុំទំនេរពីការងារភូមិ និងធ្វើស្រែ ខ្ញុំអាចធ្វើបាន។ ហើយបើសិនជាមានគេមករកទិញ ខ្ញុំអាចធ្វើឲ្យគេបាន។
As I said, I can make them when I am free from working in the rice field or seeing to affairs as the village head. And when an order is placed, I can make [Angkuoch] for that too.

*ហេតុអ្វីបានជាតាបន្ត? តារកចំណូលពីអង្គួចបានច្រើន?*
*Why do you keep making [Angkuoch]? Do you generate much income from making?*

វាមិនជាច្រើនប៉ុន្មានទេ។ វាគួរសម ប្រសិនបើខ្ញុំរកពេលធ្វើបាន។
It is not so much. It is reasonable, if I can find time to make them.

*ខ្ញុំគិតថា ប្រសិនបើតាចំណាយពេលធ្វើការងារផ្សេង តាក៏អាចរកចំណូលបានដែរ។ ហេតុអ្វីបានជាតានៅតែបន្តធ្វើអង្គួច?*
*I think if you spend time to work on other things, you can also generate some money. But why do you keep making the Angkuoch?*

ដោយសារវាជារបស់ដែលយើងធ្លាប់មានពីមុនមក ដូច្នេះ ខ្ញុំមិនអាចបំបាត់បានទេ។ ខ្ញុំត្រូវតែបន្តធ្វើ។
Because it is an instrument that Khmer used in the past, so I cannot forget it. I have to keep making it.

*ក្រៅពីធ្វើអង្គួច តាចេះធ្វើឧបករណ៍ផ្សេងៗទៀតទេ?*
*Besides from making Angkuoch, do you make other instruments?*

សព្វថ្ងៃ ខ្ញុំឈប់ធ្វើហើយ។ កាលមុន ខ្ញុំធ្វើកូនពូថៅតូចៗដែលមានឆ្លាក់រូបអង្គរ។ តែដល់ពេលក្រោយមក ខ្ញុំចាស់ ហើយងងឹតភ្នែកទើបខ្ញុំផ្អាកមួយរយៈ។ សព្វថ្ងៃ មានមនុស្សនៅធ្វើដែរ។
Now I have stopped. I used to make small axes [not musical instruments] carved with Angkor motifs. But then I got old and could not see clearly, so I stopped. Now, there are people who still make those [axes].

[06:46]

*ប៉ុន្តែតាចេះឆ្លាក់មកពីណា?*
*But where did you learn to carve?*

ខ្ញុំចេះឆ្លាក់នេះ ព្រោះខ្ញុំរៀនពីគេដែរ។ ខ្ញុំរៀនពីចាស់ៗមុនដែលចេះធ្វើ។
I knew how to carve because I learnt from other people. I learnt from old people who knew how to carve.

*ហេតុអីបានតារៀនធ្វើអង្គួច និងឆ្លាក់? ដោយសារតាស្រលាញ់ ឬមកពីវាអាចរកចំណូលបាន?*
*Why did you learn to make Angkuoch and make the carving? Is it because of your passion or it helps to generate money?*

ខ្ញុំស្រឡាញ់ផង ហើយពេលធ្វើទៅខ្ញុំលក់បានលុយដែរ។ [សើច...]
I love and when I do it, I can sell [these things] to get money. [Laughs...]

*ក្រៅពីចេះធ្វើអង្គួច តើតាចេះលេងដែរឬក៏អត់?*
*Besides from making [Angkuoch], do you also know how to play it?*

អាហ្នឹង គេហៅថាផ្ទាត់អង្គួច។ ខ្ញុំចេះដែរ។
It is called, ‘flicking Angkuoch’. I know how to do that too.

*តាចេះផ្ទាត់អង្កួចមកពីណា?*
*Who did you learn from?*

ខ្ញុំមើលគេ។ ចាស់បុរាណផ្ទាត់ ខ្ញុំផ្ទាត់តាមគាត់ដែរ។
I observed. Old people flicked, then I copied them.

[07:43]

*តារៀនផ្ទាត់តាំងពីពេលណា? ហេតុអីបានជាតាចង់ផ្ទាត់នឹងគេដែរ?*
*When did you learn to flick? And why were you interested to learn?*

ដោយសារខ្ញុំធ្វើ ដូច្នេះខ្ញុំត្រូវតែចេះផ្ទាត់។
Since I made [Angkuoch], I needed to know how to flick.

*តើតាចាំទេថាតារៀនមកពីអ្នកណា?*
*Do you remember who you learned from?*

ខ្ញុំទៅមើល(រៀន)នៅព្រះដាក់ ពីតាគើយ តែពេលនេះគាត់ស្លាប់ហើយ។ នៅភូមិនេះមានតាសោមដែលគាត់ចេះធ្វើដែរ តែគាត់ក៏ស្លាប់ហើយដែរ។
I went to Preah Dak [village] and I learned from Ta Keuy, but he passed away. In this village, Ta Som also made the Angkuoch, but he, too, already passed away.

តែដល់ពេលក្រោយមក កូនខ្ញុំទៅទិញនៅព្រះដាក់ ម្លោះហើយទើបខ្ញុំចង់ធ្វើ។ ខ្ញុំមើលគេទៅ ហើយខ្ញុំក៏ចេះ។
But later on, my son went to buy [Angkuoch] at Preah Dak. I observed the making process, then I knew how to make [Angkuoch].

[08:33]

*ជាទូទៅ តាធ្វើ ឬលេងអង្កួចនៅពេលណា?*
*Normally, when do you make and play?*

ខ្ញុំផ្ទាត់អង្កួចពេលណាដែលគេមករកទិញ ដើម្បីដឹងថាអង្កួចណាលឺ ឬអត់លឺ។ នៅពេលដែលអត់លឺ គេអត់យកទេ ព្រោះអង្កួចមិនអាចលឺទាំងអស់ទេ។
I play the Angkuoch when people come to buy one, to check the sound. If an Angkuoch can't produce a sound, buyers will not buy it. Some Angkuoch can produce a sound and some not.

*តាដឹងដោយរបៀបណា?*
*How do you know?*

កាលណាតែវារឹង ឬទន់ពេក វាអត់លឺទេ។ ខ្ញុំត្រូវធ្វើវាឲ្យល្មមទើបលឺសម្លេង។
If it is too soft or too hard, [the Angkuoch] cannot produce a sound. That is why I have to find the balance to get a good sound.

*តាដែលសម្តែងឲ្យគេមើលទេ?*
*Have you ever performed for others to see?*

អត់ទេ!អត់ដែលសម្តែងទេ។ ខ្ញុំផ្ទាត់ឲ្យតែពួកទេសចរណ៍ដែលមកទិញ។
No, I have never performed. I only play to tourists who come to buy.

[09:19]

*ចុះក្រៅពីផ្ទាត់អង្កួច តើតាលេងឧបករណ៍ផ្សេងទេ?*

*Besides from flicking Angkuoch, do you play other instruments?*

អត់ទេ! ខ្ញុំអត់ចេះទេ។ ខ្ញុំអត់លេងឧបករណ៍ផ្សេងទេ។
No, I do not play other instruments.

*អម្បាញ់មិញ គាត់ថាគាត់រៀនអង្កួចតាំងតែពីឆ្នាំ១៩៩០ជាង។ ត្រូវឬអត់?*
*Just before you said that you learned to make Angkuoch in the 1990s. Is that right?*

ត្រូវ!
Right!

*គាត់ចាំថាឆ្នាំណាឲ្យប្រាកដទេ?*
*Do you remember the exact year?*

ប្រហែលជាខួងឆ្នាំ១៩៩៣។
Perhaps in around 1993.

*តាំងតែពីគាត់ចេះធ្វើអង្កួច តើគាត់បានបង្រៀនអ្នកដទៃទៀតទេ?*
*Since you learnt about Angkuoch making, have you ever taught it to others?*

ខ្ញុំបានបង្រៀនកូន និងចៅ។
My sons and grandsons.

[09:58]

*[សូមគាត់ជួយនិយាយឃ្លាពេញបានទេ?សួរសំណួរដដែល!]*
*Can you please speak in a complete sentence? [Question is repeated.]*

ខ្ញុំបានបង្រៀនកូន និងចៅ។
I taught my sons and grandsons.

*តើកូនឬចៅរបស់គាត់ប៉ុន្មានអ្នកដែលចេះ?*
*How many of your sons can make this instrument?*

កូនរបស់ខ្ញុំពីរនាក់ដែលចេះធ្វើ
តែពេលនេះពួកគេបានផ្អាកហើយដោយសារគេរកការងារបានធ្វើ។
My two sons can make it, but they stopped now because they've got full time jobs.

[10:33]

*គាត់បង្រៀនពួកគាត់ដោយរបៀបណា?*
*How did you teach them?*

ខ្ញុំបង្រៀនពួកគេឲ្យធ្វើតាមខ្ញុំ នៅពេលដែលខ្ញុំកាប់ឬស្សី បិត ចោះ និងដាប់។
I taught them to copy me when I chop the bamboo, sharpen it, pierce and carve it.

*ហេតុអ្វីបានជាពួកគាត់មានចំណាប់អារម្មណ៍រៀនពីអង្កួច?*
*Why were they interested to learn to make Angkuoch?*

តាមការពិតទៅ ខ្ញុំឲ្យពួកគេរៀន ព្រោះនៅថ្ងៃខាងមុខ
ពួកគេអាចធ្វើវាបាននៅពេលដែលពួកគេទំនេរពីការងារ។
បើអង្កួចមិនសូវចាំបាច់ទេ យើងអាចទុកសម្រាប់បង្ហាញអ្នកក្រោយៗទៀត។
In fact, I asked them to learn, because then they could make it when they are free from work.

[11:21]

*ចុះគាត់គិតថា ហេតុអ្វីបានជាកូនរបស់គាត់គួរតែចេះធ្វើ?*
*And why you think your sons should know about Angkuoch making?*

គេគួរតែចេះ ពីព្រោះខ្ញុំចេះស្រាប់។ ណាមួយ ខ្ញុំមិនគួរចេះតែម្នាក់ឯងទេ។
They should know because I have knowledge about it. Also, I should not know about it alone.

*មានសារៈសំខាន់ដូចម្តេចទៅដែលឲ្យកូនចេះ?*
*What is the value when your sons know [how to make Angkuoch]?*

សារៈសំខាន់ត្រង់ថា យើងទំនៀមទម្លាប់នេះមានមកពីយូរហើយ។ យើងកុំបំបាត់ យើងចង់ឲ្យកូនចេះតៗគ្នាទៅមុខទៀត។
The value is that we can keep this old tradition going. We should not forget it, and I want the next generations to keep making it.

*ទម្រាំតែពួកគាត់អាចចេះ តើគាត់ត្រូវចំណាយពេលយូរប៉ុណ្ណា?*
*How long did you take to teach your sons?*

គិតទៅ វាយូរគ្រាន់ដែរ។ ប្រហែលជាមួយអាទិត្យ ព្រោះខ្ញុំត្រូវធ្វើផង ប្រាប់ពួកគេផង និង មើលពួកគេផងដើម្បីឲ្យពួកគេឆាប់ចេះលឿន។
តែការរៀនពីអង្កួចនេះមិនសូវពិបាកប៉ុន្មានទេ។
It took a bit long. Maybe one week because I had to make an instrument, and at the same time, I had to tell them how to do it, and to keep an eye on their making. Learning to make Angkuoch is not too difficult.

[12:36]

*តើគាត់បង្រៀនកូន ពេលដែលពួកគាត់អាយុប៉ុន្មានដែរ?*
*How old were your sons when you taught them?*

ប្រហែលជា១៥ ទៅ ១៦ឆ្នាំ!
Maybe around 15 to 16 years old.

*គាត់មានប្រាប់ពីរបៀបថាធ្វើយ៉ាងណាទើបសម្លេងវាពិរោះ?*
*Did you tell them the techniques to make a good sound?*

ខ្ញុំក៏បានប្រាប់ពួកគេដែរ។ ខ្ញុំឲ្យពួកគេផ្ទាត់ផង និងឲ្យពួកគេអង្កេតពីរបៀបដែលខ្ញុំធ្វើ។
I told them. I asked them to play and to watch when I made an instrument.

*គាត់ដឹងទេថា ធ្វើយ៉ាងណាទើបសម្លេងអង្កួចនេះពិរោះ?*
*How did you know whether the instrument can produce a good sound or not?*

ខ្ញុំធ្វើបណ្តើរ ខ្ញុំផ្ទាត់បណ្តើរព្រោះសម្លេងនៃអង្កួចផ្អែកលើការផ្លុំតិចឬខ្លាំង។
I played while I made, because the sound of Angkuoch depends on the breath.

*ហេតុអ្វីបានជាពេលខ្លះអង្កួចត្រូវមានសម្លេងតិច និងពេលខ្លះវាត្រូវមានសម្លេងខ្លាំង?*
*Why does it sometimes need a soft or a strong breath?*

ពីព្រោះគេត្រូវធ្វើឲ្យមានសម្លេងចុះ និងឡើង។
Because we need the sound to go up and down [to vary].

*សម្រាប់កូនរបស់គាត់ដែលចំណាយពេលមួយអាទិត្យក្នុងការរៀន*
*តើគាត់គិតថានេះជារយៈពេលលឿន ឬយូរ?*

*Your sons took a week to learn. What do you think about this length of time?*

វាមិនយឺត និងមិនលឿន។ [ សើច...] វាជាអ្វីដែលពួកគេអាចធ្វើទៅបាន។
It is not slow nor fast. It was a good time that they could learn it in.

[14:04]

*ក្រៅពីកូន និងចៅ តើតាមានបង្រៀនអ្នកណាផ្សេងទេ?*
*Besides from your sons and grandsons, did you teach others?*

មិនមានអ្នកធ្វើ និងមិនបានបង្រៀនអ្នកផ្សេងដែរ?
No one made this instrument and I did not teach others either.

*ហេតុអ្វី?*
*Why?*

ពីព្រោះគ្មានអ្នកណាចាប់អារម្មណ៍! [សើច...]
Because no one was interested! [Laughs...]

*តើតាចំណាយពេលយូរប៉ុណ្ណាក្នុងការបញ្ចុះបញ្ចូលកូនឲ្យពួកគាត់ចង់ក្នុងការធ្វើអង្កួច?*
*How long did you take to convince your sons to learn to make Angkuoch?*

ខ្ញុំមិនសូវជាចំណាយពេលយូរទេ។ ពេលមុននោះ កូនខ្ញុំបានឈប់រៀន។
តែចំណែកចៅរបស់ខ្ញុំ គេកំពុងតែរៀន តែខ្ញុំនៅតែបង្គាប់គេឲ្យចេះធ្វើ។
គេប្រហែលជាអាយុ ១៣ ទៅ ១៤ឆ្នាំ។
It did not take a long time. Before, one of my sons had dropped out from school. And my grandsons, they are still learning these days, and I still keep teaching them.

*តាបង្រៀនកូននៅឆ្នាំណាដែរ?*
*When did you teach your sons?*

ខ្ញុំចាំមិនបានទេ។ [សើច...] ខ្ញុំចាំមិនបានទេ។
I cannot remember. [Laughs...!] I cannot remember.

*ពេលនោះ តាបង្រៀនកូនមួយអាទិត្យពេញ? ឬបង្រៀនតែពេលតាហៅកូនមក?*
*At that time, did you dedicate one whole week to teach your sons? Or you just called them over to learn whenever you made the instruments?*

ខ្ញុំបង្រៀនគេឲ្យមើលខ្ញុំ និងធ្វើតាមខ្ញុំ។
ខ្ញុំក៏បង្គាប់គេថែមទៀតថាត្រូវធ្វើយ៉ាងណាទើបវាលឺសម្លេង។
ខ្ញុំបង្គាប់គេឲ្យចេះពុះឬស្សី និងហាលវាឲ្យស្ងួត។ បើសិនឬស្សីមិនស្ងួតទេ ហើយមិនសូវលឺ យើងត្រូវកំដៅភ្លើងឲ្យវារឹង និងផ្ទាត់ទៅលឺសម្លេង។
I taught them to observe and follow me in the making. I also told them about the techniques for making a good sound. I told them to chop and dry the bamboo. If the bamboo is not dried, we have to smoke the bamboo to harden it, so then it can make a good sound.

[15:44]

*ដោយសារតែអង្កួចលក់មិនបានថ្លៃ*
*តើកូនរបស់តាមានភាពស្ទាក់ស្ទើរដែរឬទេពេលដែលតាហៅគាត់មករៀនពីដំបូង?*
*Because the Angkuoch cannot be sold for a high price, were your sons reluctant to learn?*

ពួកគាត់មិនបានស្ទាក់ស្ទើរទេ ដោយសារពេលនោះពួកគាត់មិនទាន់មានការងារធ្វើ និងទំនេរ។ ដោយសារតែអាជីវកម្មអង្គួចនេះមិនអាចធ្វើបានក្នុងពេលយូរអង្វែង ដូច្នេះហើយទើបពួកគាត់ឈប់ពេលដែលមានការងារពេញម៉ោងធ្វើ។ តែពួកគេនិយាយដែរថា បើពួកគេទំនេរ និងមានគេទិញច្រើន ពួកនឹងជួយធ្វើដោយសារពួកគេចេះធ្វើស្រាប់។
They were not hesitant because they did not have full time jobs. They were free. Since the Angkuoch work was not sustainable, they stopped when they got full time jobs. But they also said that, if they are available, they will help me to make instruments, if we receive an order for Angkuoch.

*អញ្ចឹងពួកគេមានការងារធ្វើហើយអស់ហើយ?*
*So, do they have full time jobs now?*

បាទ! ពួកគេមានអស់ហើយ។ នៅតែចៅពីរនាក់ដែលនៅរៀន។ចៅៗនោះក៏ចេះដែរ។
Yes, they've all got jobs. There are only grandsons now [to make Angkuoch]. They also know how to make the instrument.

*តើតា ឬកូនរបស់តាដែលបង្រៀនចៅៗ?*
*Who taught your grandsons?*

ខ្ញុំជាអ្នកបង្រៀនចៅ។
I taught them.

*តែពួកគាត់មានបង្រៀនអ្នកផ្សេងទេ?*
*But did your sons teach others?*

អត់ទេ! ពួកគេមិនបានបង្រៀនទេ។
No, they did not teach others.

[16:57]

*ពេលដែលតាបង្រៀនកូនឲ្យធ្វើ តើតាជួបការលំបាកទេ?*
*When you taught them, was it difficult?*

មិនសូវជាពិបាកទេ! ដូចដែលខ្ញុំប្រាប់ អង្គួចនេះមិនសូវជាពិបាកទេ។ អាចបង្រៀនឲ្យឆាប់ចេះបាន!
It is not really difficult. As I said, making Angkuoch is not so hard. It can be taught with ease.

*តើធ្វើអង្គួចប្រភេទអ្វីដែរ?*
*What kind of Angkuoch do you make?*

ខ្ញុំធ្វើតែអង្គួចឬស្សី។ ចំណែកឯអង្គួចដែក ខ្ញុំតែងតែឃើញមនុស្សចាស់ ដូចជាឪពុកខ្ញុំតែងតែផ្ទាត់លេង។ វាយូរហើយ ហើយខ្ញុំមិនសូវចាំទេ។ សព្វថ្ងៃ ជាងដែកមិនចេះដំទេ។ អង្គួចដែកនេះអាចធ្វើទៅបាន លុះត្រាតែជាងដែកគេចេះដំ។
I make bamboo Angkuoch [Angkuoch Russey]. As for iron Angkuoch [Angkuoch Daek], I always saw old people, such as my father, playing it. It was a long time ago so I cannot remember well. Nowadays the blacksmith cannot make it. This instrument can be made as long as the blacksmith knows how to make it.

[17:46]

*អញ្ចឹងមានន័យថា ឪពុករបស់តាចេះលេងអង្គួចដែរ?*
*So your father knew how to play Angkuoch?*

បាទ! គាត់ចេះលេង។ ឪពុកខ្ញុំធ្វើអង្គួចដែក តែគាត់ធ្វើមិនមែនសម្រាប់លក់ទេ។ ចាស់បុរាណមិនបានលក់ដូរទៅណាទេ។ គាត់គ្រាន់តែធ្វើដើម្បីផ្ទាត់លេង និងប្រាប់គ្នីគ្នា។ ពេលណាទំនេរ គាត់អង្គុយផ្ទាត់អង្គួច។
Yes, he played. My father also knew how to make iron Angkuoch, but he did not make it for sale. People did not sell this instrument in the past. They played for fun and called each other through the instrument. When he was free, he played.

*ផ្ទាត់បែបណា?*
*How?*

ផ្ទាត់ធ្វើជាសម្លេងតូច ឬធំ ឬធ្វើជាសម្លេងលឺឆ្ងាយ ឬជិត។
They made a high or low sound and made it be heard from a far or short distance.

[18:21]

*ហេតុអ្វីបានជាចាស់ៗត្រូវការប្រើអង្គួច?*
*Why did old people have to use the Angkuoch?*

ខ្ញុំអត់ដឹងដែរ ខ្ញុំគ្រាន់តែឃើញគាត់លេង។ ខ្ញុំមិនដែលបានសួរគាត់ច្បាស់ផង។ ពេលនោះខ្ញុំនៅតូច ហើយមិនដឹងថាគាត់លេងយ៉ាងម៉េចផង។
I don't know about that. I just saw them playing. I never asked them for the details. At that time I was young, and I did not know how they played it.

*ពេលនោះ គាត់លេងជាមួយអ្នកណាដែរ?*
*At that time, who did your father play with?*

គាត់លេងតែឯង។ តែម្នាក់គាត់។
He played alone. Only by himself.

*មិនមែនលេងនៅជុំចាស់ៗទេ?*
*Didn't he play together?*

មិនបាច់ជុំចាស់ៗក៏បាន!
It was okay not to play in a group.

*តែគាធ្លាប់ឃើញគាត់ជុំគ្នា ហើយលេងដែរឬអត់?*
*But had you ever seen him playing in a group?*

មិនដែលឃើញគាត់ជុំគ្នាទេ! គាត់ផ្ទាត់តែម្នាក់គាត់។
I never saw him playing in a group. He always played alone.

*គាដែលសួរគាត់ពីឧបករណ៍នេះទេ?*
*Did you ever ask him anything about this instrument?*

ទេ!  ខ្ញុំមិនដែលបានសួរគាត់ផង។ ដូចខ្ញុំថា ពេលនោះខ្ញុំនៅតូច។
No, I did not. As I said, I was very little at that time.

[19:10]

*គាគិតថាអ្នកណាគួរតែរៀនលេង និងធ្វើអង្គួច?*
*Who do you think should learn to play and make this instrument?*

មានតែក្មេងក្រោយៗ! អ្នកខ្លះ គេមិនសូវចាប់អារម្មណ៍។ ពីដើមមុន អង្គួចនេះមិនសូវមានអ្នកទិញច្រើន។ មានអ្នកទិញតែមួយចំនួនតូច។
The younger generation! But some people, they are not interested. [Even] before, there were not many people who bought this instrument, only a small number of people.

*តាមានអារម្មណ៍យ៉ាងណាពេលដែលគេមិនសូវខ្វល់ពីអង្គួច?*
*How do you feel when people are not interested in Angkuoch?*

ខ្ញុំមានអារម្មណ៍ថាស្តាយដែរ។ស្តាយរបស់ដែលធ្វើងាយ!
I feel regret. It is regretful because this instrument is easily made.

*ហេតុអ្វីបានជាតាស្តាយ?*
*Why do you feel regretful?*

ស្តាយដែលគេមិនយកចិត្តទុកដាក់!
I feel regretful because people don’t pay attention to it.

[20:18 - END]